ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No ១៥៩ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## នីតិវិធី ចេញ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ

*******

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញរាជក្រមលេខ នស/ រកម/ ០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមស្មារតីអង្គប្រជុំអនុគណៈកម្មការសំរបសំរួលពាណិជ្ជកម្មដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤ ប្រារព្ធធ្វើនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កន្លងមក ។

## សំរេច

**ប្រការ ១ :** បែបបទនាំចេញទំនិញវាយនភ័ណ្ឌ និង ផលិតផលធ្វើពីស្បែក តាមប្រព័ន្ធអនុគ្រោះ MFN/GSP ត្រូវបានកំណត់ដូចខាងក្រោម :

ក- ការងារត្រួតពិនិត្យអធិការកិច្ច ផលិតកម្ម និង ផលិតផលនាំចេញធ្វើដោយមន្ត្រីជំនាញរបស់ក្រសួងពាណិជ្ជកម្ម និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវបានដំណើរការរួមគ្នានៅតាមមូលដ្ឋានផលិតកម្មនៅក្រោយពេលទំនិញត្រូវបាននាំចេញរួចហើយ និង ទទួលបានឯកសារបញ្ជាក់ប្រភពដើមទំនិញ (C/O, C/I, និង E/L) ពីក្រសួងពាណិជ្ជកម្ម ។

ខ- របាយការណ៍ផលិតកម្ម និង ទំនិញនាំចេញមួយ ត្រូវបានធ្វើឡើង និង ចុះហត្ថលេខារួមគ្នាមកពី :

- មន្ត្រីអធិការកិច្ចទំនិញនៃក្រសួងឧស្សាហកម្ម ចំនួន ០១ រូប
- មន្ត្រីអធិការកិច្ចទំនិញនៃក្រសួងពាណិជ្ជកម្ម ចំនួន ០១ រូប ឬ ០២ រូបក្នុងករណីជាប់ Export License ។

គ- ដំណើរការអធិការកិច្ចនេះ គឺជាកាតព្វកិច្ចតំរូវអោយគ្រប់អ្នកនាំចេញត្រូវសហការណ៍ជាមួយមន្ត្រីទាំងពីរស្ថាប័ន ដើម្បីបញ្ជាក់ដំណើរផលិតកម្ម-សមត្ថភាពផលិតកម្ម-ការជួលផលិតធានាភាពសមស្របក្នុងការអនុវត្តន៍វិធានប្រភពដើមទំនិញ និង សំរាប់ជាមូលដ្ឋាននៃការចេញវិក័យប័ត្រពាណិជ្ជកម្ម (C/I) . វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O) និង អាជ្ញាប័ណ្ណនាំចេញ (E/L) នៅជំហាន បន្ទាប់ទៀត ។

ឃ- ដំណើរការស្នើសុំ វិក័យប័ត្រពាណិជ្ជកម្ម (C/I) . វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O) និង អាជ្ញាប័ណ្ណនាំចេញ (E/L) តាមមធ្យោបាយផ្លូវទឹក និង ផ្លូវអាកាសត្រូវភ្ជាប់មកជាមួយ នូវឯកសារចាំបាច់មួយចំនួនដូចខាងក្រោមនេះ :

- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនាំចេញ នីហរ័ណ-អាហរ័ណ និង បង្រ្កាបការក្លែងបន្លំ "កាំកុងត្រូល" និង ទីចាត់ការគយ និង រដ្ឋាករ ។
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- វិក័យប័ត្រ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- កិច្ចសន្យាទិញលក់ (Sale Contract)
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)
- មូលប្បទានប័ត្រសំរាប់សោហ៊ុយរដ្ឋបាល ឬ សំរាប់គំរៃ Quota នាំចេញ ឬគំរៃនាំចេញ ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile (855-23) 213288
URL : http://www.moc.gov.kh E-Mail champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile (855-23) 426396

**ប្រការ ២** : បែបបទនាំចេញខាងលើត្រូវកំណត់អោយបង់សោហ៊ុយរដ្ឋបាល និង កំរៃនាំចេញដូចខាងក្រោម :

- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O)
  - * ទំរង់ N (Form N) = ៣០ USD ក្នុង ០១ ច្បាប់
  - * ទំរង់ A (Form A) = ៥០ USD ក្នុង ០១ ច្បាប់
- អាជ្ញាប័ណ្ណនាំចេញ = ១៥,០០០ រៀល ក្នុង ០១ ច្បាប់
- វិក័យប័ត្រពាណិជ្ជកម្ម (Commercial Invoice) = ១២០,០០០ រៀល ក្នុង ០១ ច្បាប់

ក្នុងករណើទំនិញដែលនាំចេញទៅកាន់សហគមន៍អឺរ៉ុប និង ប្រទេសក្រៅពីសហរដ្ឋអាមេរិក ត្រូវបង់ :

ក- លើទំនិញវាយនភ័ណ្ឌ និង សំលៀកបំពាក់ បរិមាណក្រោម ២,០០០ Pieces ឬ ស្បែកជើង បរិមាណក្រោម ២០០ គូរ គឺ :

- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O)
  ទំរង់ N (Form N) = ១០ ដុល្លាអាមេរិក ក្នុង ០១ ច្បាប់
- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O)
  ទំរង់ A (Form A) = ១៥ ដុល្លាអាមេរិក ក្នុង ០១ ច្បាប់

ខ- កំរៃលើវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញនាំចេញសំលៀកបំពាក់គ្រប់ប្រភេទ ទៅកាន់សហគមន៍អឺរ៉ុប និង ក្រៅសហគមន៍អឺរ៉ុប ស្មើរនឹង ០.១០ ដុល្លាអាមេរិក / ឡូតិ៍ ។

**ប្រការ ៣** : ចាប់ពីពេលដាក់ពាក្យស្នើសុំ នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ឬ នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស រហូតដល់ការប្រគល់ឯកសារ វិក័យប័ត្រពាណិជ្ជកម្ម (C/I), វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O) និងអាជ្ញាប័ណ្ណនាំចេញ (E/L) មានរយៈពេល ១១ ម៉ោង ៥៥ នាទី ។

**ប្រការ ៤** : កំណត់សុពលភាពនៃការប្រើប្រាស់ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ, វិក័យប័ត្រពាណិជ្ជកម្ម, អាជ្ញាប័ណ្ណនាំចេញ (By Air) មានរយៈពេល ៣០ ថ្ងៃ ( សាមសិបថ្ងៃ ) ។

**ប្រការ ៥** : នៅកន្លែងទទួលពាក្យរបស់នាយកដ្ឋានអនុគ្រោះពាណិជ្ជកម្ម និង នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ត្រូវមានការចូលរួមសង្កេតការណ៍ពីសំណាក់មន្ត្រីអធិការកិច្ចនៃក្រសួងពាណិជ្ជកម្ម និង តំណាងសមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា (GMAC) ដើម្បីតាមដានការបញ្ជាក់ការចុះថ្ងៃ-ខែ និង ពេលវេលាលើបង្កាន់ដៃទទួលពាក្យ និង លើឯកសារប្រគល់-ទទួលសំណុំរឿង



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones (855-12) 933 323 / 881223 Facsimile: (855-23) 426396

ប៉ុន្តែមិនមានការជ្រៀតជ្រែកក្នុងកិច្ចការជំនាញរបស់នាយកដ្ឋានទេ ។

**ប្រការ ៦ :** អគ្គាធិការ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានគាំពុងត្រួល , នាយិកាខុទ្ទកាល័យ ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤ ។

**ប្រការ ៧ :** ប្រកាស និង លិខិតជូនដំណើរដែលមានលក្ខណៈផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

ចម្លងជូន :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សោ ខាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- ស្ថានឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមអ្នកកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*File. Prakas on new procedure for the issuance of C/I, C/O and E/L*

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones (855-12) 933 323 / 881223 Facsimile (855-23) 426396